NSW GOVERNMENT | Health

# សារធាតុថ្នាំ Naphthalene មាននៅក្នុងដុំថ្នាំការពារសត្វខ្មូត និងបន្ទះថ្នាំបំបាត់ក្លិនបង្គន់

## What is Naphthalene / តើ Naphthalene ជាអ្វី?

ដុំថ្នាំការពារសត្វខ្មូត និងបន្ទះថ្នាំបំបាត់ក្លិនបង្គន់ខ្លះ មានសារធាតុថ្នាំម្យ៉ាងឈ្មោះ naphthalene (ណេបថាលីន)។ Naphthalene គឺជាសារធាតុដុំសមួយមានសណ្ឋានរឹង មានខ្លិនខុសប្លែកគេ ហើយតាមធម្មតា គេឃើញមាននៅក្នុងប្រេងហ្វូស៊ីល ដូចជាធ្យូង និងប្រេងឥន្ធនៈជាដើម។

## តើខ្ញុំអាចដាក់ប៉ះចំសារធាតុថ្នាំ Naphthalene ដោយបែបណា?

ការដាក់ប៉ះចំសារធាតុថ្នាំ naphthalene អាចកើតមានឡើង ប្រសិនបើអ្នកដកដង្ហើមស្រូបយកខ្យល់ដែលមានសារធាតុថ្នាំ naphthalene ប្រសិនបើអ្នកពិសាវត្ថុរាវដែលមានសារធាតុថ្នាំ naphthalene ឬប្រសិនអ្នកចាប់ប៉ះ ឬពិសាផលិតផលដែលមានសារធាតុថ្នាំ naphthalene ដោយអចេតនា។ ត្រូវប្រយ័ត្នថា អ្នកក៏អាចដកដង្ហើមស្រូបយកក្លិនសារធាតុថ្នាំ naphthalene ចេញពីសម្លៀកបំពាក់ដែលបានទុកដាក់ជាមួយថ្នាំការពារសត្វខ្មូតផងដែរ។

## តើសារធាតុថ្នាំ naphthalene អាចមានផលប៉ះពាល់ដល់សុខភាពយ៉ាងណាដែរ?

ការដាក់ប៉ះចំ naphthalene ដែលមានចំនួនច្រើនក្រៃលែង អាចបណ្តាលឲ្យខូចខាតដល់កោសិកាឈាមដែលនាំឲ្យកើតមានរោគមួយហៅថា haemolytic anaemia។ រោគនេះគេឃើញមាននៅក្នុងមនុស្ស ជាពិសេសនៅក្នុងចំណោមកូនក្មេង ក្រោយពីគេបានញ៉ាំប៉ះថ្នាំការពារសត្វខ្មូតដែលមានសារធាតុថ្នាំ naphthalene។ រោគសញ្ញាខ្លះៗដែលអាចកើតមាន បន្ទាប់ពីបានដាក់ប៉ះចំសារធាតុថ្នាំ naphthalene ចំនួនយ៉ាងច្រើនមានដូចជាការអស់កម្លាំង លែងឃ្លានចំណីអាហារ ដំណើរចង់ក្អួត ក្អួត និងចុះរាគ។ ស្បែកអាចទៅជាស្លេកស្លាំង ឬមានសម្បុរលឿង។ ទារកដែលទើបកើត ជាពិសេសស្ថិតនៅក្នុងភាពប្រឈមនឹងគ្រោះថ្នាក់នៃការខូចខាតដល់កោសិកាឈាម ប្រសិនបើដាក់ប៉ះចំសារធាតុថ្នាំ naphthalene។ ការខូចខាតដល់កោសិកាឈាមបញ្ចេញនូវសារធាតុមួយ (bilirubin) ដែលនាំឲ្យទារកទៅជាពណ៌លឿង ហើយនៅក្នុងករណីដ៏ធ្ងន់ធ្ងរ នាំឲ្យខូតដល់ខួរក្បាល។ មនុស្សខ្លះកើតមកមានរោគឈាមតពូជហៅថា (G6PD deficiency) ជាហេតុនាំឲ្យគេងាយនឹងទទួលផលប៉ះពាល់ពីសារធាតុថ្នាំ naphthalene។ ហេតុនេះ រោគសញ្ញាអាចឃើញមាន ទោះបីជាដាក់ប៉ះចំសារធាតុថ្នាំ naphthalene ដែលមានចំនួនតិចក្តី។ ប្រសិនបើរោគសញ្ញាទាំងនេះណាមួយកើតមានឡើង បន្ទាប់ពីដាក់ប៉ះចំសារធាតុថ្នាំ naphthalene អ្នកគួរពិគ្រោះជាមួយវេជ្ជបណ្ឌិតឲ្យបានភ្លាមៗ។ ពុំឃើញមានភស្តុតាងចំផ្ទាល់បង្ហាញថាសារធាតុថ្នាំ naphthalene អាចបណ្តាលឲ្យកើតរោគមហារីកនៅក្នុងចំណោមមនុស្សឡើយ។

## តើគួរប្រើប្រាស់សារធាតុថ្នាំ naphthalene ដោយសុវត្ថិភាពក្នុងបែបណា?

ថ្នាំការពារសត្វខ្មូតដែលមានសារធាតុថ្នាំ naphthalene ជាទូទៅ មានសុវត្ថិភាពសំរាប់ប្រើប្រាស់ក្នុងចំណោមមនុស្សជំទង់ និងក្មេងធំ ប្រសិនបើបានប្រើប្រាស់ត្រឹមត្រូវ ហើយក្នុងចំនួនត្រឹមត្រូវ។ គោលការណ៍ណែនាំអូស្ត្រាលីបានណែនាំថាការប្រើប្រាស់សារធាតុថ្នាំ naphthalene ត្រូវបានដាក់កំហិតចំពោះកុមារអាយុក្រោមបីឆ្នាំ។ ការនេះមានន័យថាភួយ និងសម្លៀកបំពាក់របស់កុមារមិនគួរទុកដាក់ជាមួយថ្នាំការពារសត្វខ្មូតដែលមានសារធាតុថ្នាំ naphthalene ឡើយ ហើយក៏មិនគួរប្រើប្រាស់ថ្នាំការពារសត្វខ្មូតនៅក្នុងបន្ទប់កុមារ ឬទីកន្លែងដែលមានកុមារនៅ ឬចេញចូលឡើយ។ ប្រសិនបើភួយ និងសម្លៀកបំពាក់របស់កុមារត្រូវបានទុកដាក់ជាមួយថ្នាំការពារសត្វខ្មូតដែលមានសារធាតុថ្នាំ naphthalene ដោយអចេតនា គួរយកភួយ និងសម្លៀកបំពាក់ទាំងនោះទៅដាក់សំដិលហាលខ្យល់ក្រៅផ្ទះដើម្បីបំបាត់ក្លិន ហើយបោកសំអាត មុននឹងយកប្រើប្រាស់។

វាអាចមានគ្រោះថ្នាក់ខ្លាំងណាស់ ប្រសិនបើពិសាចំថ្នាំការពារសត្វខ្មូត។ ហេតុនេះហើយវាជាការសំខាន់ជាពិសេស ដែលត្រូវរក្សាទុកថ្នាំការពារសត្វខ្មូតឲ្យបានផុតពីដៃក្មេងតូចៗ និងសត្វចិញ្ចឹម។

ជាបន្ថែម ប្រសិនបើអ្នក ឬមានសមាជិកគ្រួសារជិតស្និទ្ធរបស់អ្នកណាម្នាក់ត្រូវបានធ្វើរោគវិនិច្ឆ័យថាមានរោគឈាមតពូជ នោះគួរចៀសវាងផលិតផលដែលមានសារធាតុថ្នាំ naphthalene។

*ឱវាទបន្ថែមទាក់ទិនភាពប្រថុយនឹងគ្រោះថ្នាក់កើតមានពីសារធាតុថ្នាំ naphthalene អាចទទួលយកបាន២៤ម៉ោងក្នុង១ថ្ងៃ ៧ថ្ងៃក្នុង១អាទិត្យ ពេញទូទាំងប្រទេសអូស្ត្រាលី ពីមជ្ឈមណ្ឌល NSW Poisons Information Centre តាមទូរស័ព្ទលេខ 13 11 26 ឬពី Public Health Units ក្នុងតំបន់។*

| **Metropolitan Areas** | **Hornsby** | **Number** | **Rural Areas** | **Location** | **Number** |
|---|---|---|---|---|---|
| Northern Sydney/Central Coast | Hornsby | 02 9477 9400 | Greater Southern | Goulburn | 02 4824 1837 |
| | Gosford | 02 4349 4845 | | Albury | 02 6080 8900 |
| South Eastern Sydney/ Illawarra | Randwick | 02 9382 8333 | Greater Western | Broken Hill | 08 8080 1499 |
| | Wollongong | 02 4221 6700 | | Dubbo | 02 6841 5569 |
| Sydney South West | Camperdown | 02 9515 9420 | | Bathurst | 02 6339 5601 |
| Sydney West | Penrith | 02 4734 2022 | Hunter/New England | Newcastle | 02 4924 6477 |
| | Parramatta | 02 9840 3603 | | Tamworth | 02 6767 8630 |
| Justice Health Service | Matraville | 02 9311 2707 | North Coast | Port Macquarie | 02 6588 2750 |
| | | | | Lismore | 02 6620 7500 |

សូមមើលពត៌មានពិស្តារពេញលេញរបស់ Public Health Units នៅតាមវ៉ិបសាយ www.health.nsw.gov.au/publichealth/infectious/phus.asp

## សេវាអ្នកបកប្រែភាសា

ប្រសិនបើលោកអ្នកត្រូវជំនួយដើម្បីទាក់ទងជាមួយសេវាទាំងឡាយខាងលើនេះ ឬសេចក្តីបកប្រែ សូមទូរស័ព្ទ Translating and Interpreting Service (TIS) លេខ 13 14 50។

សំរាប់ពត៌មានពហុភាសាផ្នែកសុខភាពឯទៀត សូមមើលវ៉ិបសាយ www.mhcs.health.nsw.gov.au